THE SCHOOL DISTRICT OF PHILADELPHIA ការណែនាំសម្រាប់មាតាបិតា

# PASA: ប្រព័ន្ធវាយតម្លៃសាលាតាមវិធីផ្សេងទៀតរបស់រដ្ឋផិនស៊ីលវេនញ៉ា

## តើការប្រឡង PASA គឺជាអ្វី?

ច្បាប់សម្រាប់សិស្សពិការនៃឆ្នាំ២០០៤ (IDEA) តម្រូវឲ្យរដ្ឋ និងភ្នាក់ងារអប់រំក្នុងតំបន់ (LEAs) ធ្វើយ៉ាងណាឲ្យក្មេងពិការទាំងអស់ចូលរួមក្នុងកម្មវិធីវាយតម្លៃសិស្សទូទៅរបស់រដ្ឋ និងទូទាំងក្រសួងអប់រំទាំងអស់។ ប្រព័ន្ធវាយតម្លៃសិស្សតាមវិធីផ្សេងទៀតនៅរដ្ឋផិនស៊ីលវេនញ៉ា (PASA) បានបង្កើតឡើងតាមការអនុលោមជាមួយការអនុញ្ញាតនេះដើម្បីឲ្យត្រូវតាមសេចក្តីត្រូវការរបស់សិស្សដែលពិការធ្ងន់ធ្ងរក្នុងការយល់ដឹង ដែលមិនអាចចូលរួមក្នុងការវាយតម្លៃសិស្សទូទៅបាន ទោះជាមានការផ្តល់ជំនួយតាមតម្រូវការក៏ដោយ។ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា បានសហការជាមួយ Dynamic Learning Maps ដើម្បីបង្កើតកំណែថ្មីនៃការប្រឡង PASA។

### តើមានន័យដូចម្តេចចំពោះពាក្យ Emerging, Approaching Target, At Target, ឬ Advanced?

កម្រិតនៃការប្រឡងត្រូវបានឲ្យនិយមន័យដូចតទៅ៖

- **Emerging**: សិស្សបង្ហាញឲ្យឃើញថាចាប់ផ្តើមយល់ដឹង ហើយអាចប្រើចំណេះដឹង និងការប៉ិនប្រសប់ដែលបង្ហាញឲ្យឃើញដោយចំណុចសំខាន់ៗ។
- **Approaching Target**: សិស្សយល់ដឹង និងអាចប្រើចំណេះដឹង និងការប៉ិនប្រសប់នៃអ្វីៗដែលបានកំណត់ទុកជាមុន ដែលបង្ហាញឲ្យឃើញដោយចំណុចសំខាន់ៗទៅកាន់កម្រិតដែលបានកំណត់ទុកជាមុន។
- **At Target**: សិស្សយល់ដឹង និងអាចប្រើចំណេះដឹង និងការប៉ិនប្រសប់នៃអ្វីៗដែលបានកំណត់ទុកជាមុន ដែលបង្ហាញឲ្យឃើញដោយចំណុចសំខាន់ៗបានតាមកម្រិតកំណត់ទុកមុន។
- **Advanced**: សិស្សបង្ហាញឲ្យឃើញពីកម្រិតយល់ដឹង និងសមត្ថភាពប្រើចំណេះដឹង និងការប៉ិនប្រសប់តាមកម្រិតខ្ពស់ បង្ហាញឲ្យឃើញដោយចំណុចសំខាន់ៗនៃ ភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។

## តើការប្រឡង PASA វាយតម្លៃអ្វី?

ការប្រឡង PASA វាយតម្លៃសមិទ្ធិកម្មនៃចំណេះដឹង និងការប៉ិនប្រសប់របស់ក្មេងដែលពិការធ្ងន់ធ្ងរក្នុងការយល់ដឹង តាមរយៈនៃការធ្វើកិច្ចការ។ ការវាយតម្លៃនេះគឺជាការស្របតាមស្តង់ដារវិជ្ជាសិក្សារបស់រដ្ឋផិនស៊ីលវេនញ៉ា ដោយកាត់បន្ថយជម្រៅ និងទំហំ។ ដូចគ្នានឹងការប្រឡងខ្នាតស្តង់ដារទូទាំងរដ្ឋដែរ (ប្រព័ន្ធវាយតម្លៃសិស្សរដ្ឋផិនស៊ីលវេនញ៉ា ឬ PSSA) គោលបំណងនៃការប្រឡង PASA គឺដើម្បីផ្តល់ព័ត៌មានដល់ក្រសួងអប់រំ និងក្រុមផ្តល់សេវាអប់រំផ្សេងទៀត ដែលនឹងជួយពួកគេក្នុងការកែលម្អការបង្ហាត់បង្រៀនសម្រាប់ក្មេង។ ការប្រឡង PASA ត្រូវធ្វើសម្រាប់ថ្នាក់ទី៣-៨ និង ទី១១ ទាំងភាសាអង់គ្លេស និងគណិតវិទ្យា និងថ្នាក់ទី៥ ទី៨ និងទី១១ វិទ្យាសាស្ត្រ។ **ដើម្បីយល់ពីជម្រៅនៃមុខវិជ្ជាដែលសិស្សប្រឡង PASA ផ្នែកអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ សូមមើល ប្លង់ឯកសា សម្រាប់ប្រធានបទនីមួយៗ។**

## តើសិទ្ធិសម្រាប់ការប្រឡង PASA សម្រេចដោយរបៀបណា?

ការសម្រេចចិត្តនេះធ្វើឡើងដោយក្រុម IEP នៅសាលារបស់លោកអ្នក។ ក្រុម IEP ប្រើ ឧបករណ៍រួមផ្សំសម្រាប់លក្ខណៈវិនិច្ឆ័យនៃសិទ្ធិប្រឡង PASA (PASA Eligibility Criteria Companion Tool) ដើម្បីសម្រេចថាតើសិស្សត្រូវតាមតម្រូវការទាំងប្រាំមួយឬអត់។ ក្រុម IEP ត្រូវឆ្លើយ *បាទ/ចាស* ទៅនឹងលក្ខណៈវិនិច្ឆ័យទាំងប្រាំមួយ ទើបកូនលោកអ្នកអាចចូលរួមក្នុងការប្រឡង PASA បាន។

## តើកូនខ្ញុំនឹងប្រឡង PASA នៅពេលណា?

ការប្រឡង PASA ត្រូវធ្វើឡើងប្រចាំឆ្នាំ ដែលមានរយៈពេលប្រឡង តាមធម្មតាបើកនៅរដូវស្លឹកឈើជ្រុះ គឺខែមិនា មេសា និងឧសភា។ លោកអ្នកអាចមើល ប្រតិទិនសម្រាប់ការប្រឡងរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ ព្រមទាំងប្រតិទិនសាលារបស់កូនលោកអ្នក សម្រាប់កាលបរិច្ឆេទជាក់លាក់នៃពេលប្រឡង PASA នៅសាលារបស់ពួកគេ។

## តើគ្រួយកលទ្ធផលនៃការប្រឡង PASA របស់កូនខ្ញុំទៅធ្វើអ្វី?

ពិន្ទុរបស់សិស្សម្នាក់ៗផ្តល់ទៅឲ្យតែសាលារបស់កូនលោកអ្នកតែប៉ុណ្ណោះ អាចប្រើដើម្បីជួយគ្រូក្នុងការធ្វើឲ្យដឹងពីភាពខ្លាំងពូកែ និងភាពអន់ខ្សោយរបស់កូនលោកអ្នក។ បន្ទាប់មកអនុញ្ញាតឱ្យគ្រូរៀបចំការបង្ហាត់បង្រៀន និងការហ្វឹកហាត់ដែលល្អសម្រាប់កូនលោកអ្នក ដើម្បីការគាំទ្រដ៏ល្អបំផុតដល់ការរីកចម្រើនក្នុងការសិក្សារបស់ពួកគេ។ ពិន្ទុប្រឡង PASA ក៏ផ្តល់ព័ត៌មានដល់សាលា និងក្រសួងអប់រំដែលអាចគាំទ្រការកែលម្អ និងការរៀបចំផែនការពិភាក្សាពីកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន ផងដែរ។

## តើពិន្ទុប្រភេទណាដែលរាយការណ៍នៅលើការប្រឡង PASA?

របាយការណ៍ពិន្ទុរបស់សិស្សម្នាក់ៗមានពីរផ្នែក។ ផ្នែកទីមួយនៃរបាយការណ៍ពិន្ទុគឺ លទ្ធផលនៃប្រវត្តិសិក្សា ដែលផ្តល់ព័ត៌មានទូលំទូលាយអំពីអ្វីដែលសិស្សដឹង និងអាចធ្វើ នៅក្នុងប្រធានបទទាំងអស់។ ផ្នែកទីពីរនៃរបាយការណ៍ពិន្ទុគឺ ប្រវត្តិសិក្សា ដែលផ្តល់ព័ត៌មានជាក់លាក់អំពីជំនាញដែលសិស្សចេះស្ទាត់។ ដើម្បីជ្រាបព័ត៌មានបន្ថែមពីប្រធានបទនេះ លោកអ្នកអាចមើល ការណែនាំអំពីរបាយការណ៍ពិន្ទុនៃការប្រឡង PASA។

## តើការប្រឡង PASA កំណត់ម៉ោងដែរឬទេ?

ការប្រឡង PASA មិនកំណត់ម៉ោងទេ ប៉ុន្តែសិស្សមិនអាចបញ្ចប់ផ្នែកណាមួយ - ក៏ហៅថា testlet (សំណួរច្រើនក្នុងប្រធានបទតែមួយ) – ក្នុងរយៈពេលច្រើនថ្ងៃបានទេ។ ឧទាហរណ៍ ប្រសិនបើសិស្សចាប់ផ្តើម testlet នៅថ្ងៃច័ន្ទ ពួកគេមិនអាចបញ្ចប់ testlet នៅថ្ងៃអង្គារបានទេ។

## តើការប្រឡង PASA ប៉ះពាល់ដល់ពិន្ទុរបស់កូនខ្ញុំដែរឬទេ?

ការប្រឡងនេះមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ។

## តើកូនខ្ញុំប្រឡង PASA ដោយរបៀបណា?

ការប្រឡង PASA ធ្វើតាមការប្រើកុំព្យូទ័រ។ ទោះជាដូច្នេះក៏ដោយ សិស្សត្រូវតែទៅប្រឡងនៅសាលារបស់ពួកគេផ្ទាល់។

## តើខ្ញុំអាចមើលលទ្ធផលនៃការប្រឡង PASA នៅទីណា?

សាលាទទួលរបាយការណ៍របស់សិស្សម្នាក់ៗជាច្រើនច្បាប់ក្នុងមួយឆ្នាំៗ ពីរបីខែក្រោយពេលបិទការប្រឡង។ លោកអ្នកអាចស្នើសុំរបាយការណ៍របស់សិស្សម្នាក់ៗមួយច្បាប់ពីសាលារបស់កូនលោកអ្នក។ លទ្ធផលក៏ចុះផ្សាយក្នុងគេហទំព័រសម្រាប់មាតាបិតាក្រោមផ្នែកប្រឡងខ្នាតស្តង់ដារ (Standardized Test) នៃព័ត៌មានរបស់សិស្សផងដែរ។

## តើខ្ញុំអាចទាក់ទងទៅអ្នកណាបើខ្ញុំមានសំណួរថែមទៀតអំពីការប្រឡង PASA?

ប្រសិនបើលោកអ្នកមានសំណួរថែមទៀតអំពីការប្រឡង PASA យើងសូមឱ្យលោកអ្នកទាក់ទងទៅសាលារបស់កូនលោកអ្នក។ ព័ត៌មានសម្រាប់ទាក់ទងទៅសាលារបស់កូនលោកអ្នកអាចយកពីវិបសៃផ្ទុកព័ត៌មានសាលា ថ្មី របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមអំពីការប្រឡង PASA នៅទីណា?

ការិយាល័យវាយតម្លៃសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖
https://www.philasd.org/research/#assessmentsera

Dynamic Learning Maps (ឈ្មួញ PASA): https://dynamiclearningmaps.org/pennsylvania

គេហទំព័រស្តីអំពី PASA របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ិលវេនញ៉ា៖
https://www.pa.gov/agencies/education/programs-and-services/instruction/elementary-and-secondary-education/assessment-and-accountability/pennsylvania-alternate-system-of-assessment-pasa.html